# បេឡាជាតិសន្តិសុខសង្គម
National Social Security Fund

# អត្ថប្រយោជន៍នៃរបបសន្តិសុខសង្គម ផ្នែកសេវាស្តារនីតិសម្បទា




១២៨៦

សេវាផ្តល់ព័ត៌មានទូទៅ ដោយឥតគិតថ្លៃ


ភូមិបន្លាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

០២៣ ៨៨២ ៤៣៤/០២៣ ៨៨២ ៦២៣

www.nssf.gov.kh

www.facebook.com/nssfpage

nssfcambodia


រៀបចំដោយ ៖ នាយកដ្ឋានស្តារនីតិសម្បទា

## បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)

ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលមានភារកិច្ចគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គម អនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលរួមមានផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ សម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ និងបុគ្គលស្វ័យនិយោជន៍។

## តើសេវាស្តារនីតិសម្បទាជាអ្វី?

គឺជាតារកាលិក ឬអត្ថប្រយោជន៍នៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ដែលផ្តល់ឱ្យសមាជិកនៅពេលជួបហានិភ័យការងារ គ្រោះថ្នាក់ ឬជំងឺ រហូតដល់ធ្លាក់ខ្លួនពិការភាព។ សេវាស្តារនីតិសម្បទានេះសំដៅដល់ការផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ និងសេវាសង្គម ក្នុងគោលបំណងជួយដល់ជនមានពិការភាពអាចរក្សា ស្តារ ឬធ្វើឱ្យប្រសើរឡើងវិញនូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ ដែលបានបាត់បង់ ឬខូចខាតដោយសារជំងឺ ការរងរបួស ឬពិការភាព។

## សេវាស្តារនីតិសម្បទានៅក្នុងរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ

សមាជិក ប.ស.ស. ដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ឬពិការភាព មានសិទ្ធិទទួលបានសេវាស្តារនីតិសម្បទា ដែលរួមមានសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ឬសេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ឬសេវាសង្គម៖

### ១. សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ

សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ត្រូវបានផ្តល់ជូនសមាជិក ប.ស.ស. ដែលទទួលរងហានិភ័យការងារ សម្រាប់គាំទ្រដល់ការព្យាបាល និងថែទាំវេជ្ជសាស្ត្រ ឬសម្រាប់ជួយសម្រួលដល់ជនរងគ្រោះដែលបានបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ឬពិការភាព។

សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ សំដៅដល់ការផ្តល់ ការជួសជុល ឬការផ្តល់ជាថ្មីអវយវៈសិប្បនិម្មិត រណប ឬឧបករណ៍ជំនួយ ការហ្វឹកហាត់កាយសម្បទាឡើងវិញ ការព្យាបាលដោយចលនា និងការផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រដទៃទៀត។



អវយវៈសិប្បនិម្មិត រណប និងឧបករណ៍ជំនួយ









## ២. សេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ

សេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ត្រូវបានផ្តល់ជូនសមាជិក ប.ស.ស. ដែលធ្លាក់ខ្លួនពិការដោយហានិភ័យការងារ ដើម្បីមានឱកាសទទួលបានការងារ ឬមុខរបរថ្មីស្របតាមកាយសម្បទារបស់ខ្លួន។

ជនមានពិការភាពដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែង អាចទទួលបានការជួយសម្របសម្រួលរកការងារឱ្យធ្វើ។









## ៣. សេវាសង្គម

ជនមានពិការភាពដោយហានិភ័យការងារ មានសិទ្ធិទទួលបាននូវការប្រឹក្សា ការតម្រង់ទិស ការអប់រំចិត្តសាស្ត្រ និងសេវាសង្គមនានា ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវផ្នែកចិត្តសាស្ត្រសង្គម ទទួលបានភាពម្ចាស់ការ ស្របតាមស្ថានភាពរស់នៅប្រចាំថ្ងៃ។







## សេវាស្តារនីតិសម្បទានៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

សមាជិក ប.ស.ស. ដែលទទួលរងគ្រោះថ្នាក់ ឬជំងឺ ក្រៅពីហានិភ័យការងារ ត្រូវទទួលបានតែសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រប៉ុណ្ណោះ ដែលសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រនេះដូចមានលើកឡើងនៅក្នុងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ។

## តើធ្វើដូចម្តេចដើម្បីទទួលបានសេវាស្តារនីតិសម្បទា?

- ✓ សមាជិក ប.ស.ស. ត្រូវទំនាក់ទំនងមន្ត្រី ប.ស.ស. នៅស្នាក់ការកណ្តាល ឬតាមសាខារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលនៅជិត ដើម្បីទទួលបានព័ត៌មាន និងជួយសម្របសម្រួលដល់ការស្នើសុំ
- ✓ ការដាក់ពាក្យស្នើត្រូវភ្ជាប់មកជាមួយនូវប័ណ្ណសមាជិក ប.ស.ស. និងឯកសារពាក់ព័ន្ធផ្សេងៗទៀតក្នុងករណីចាំបាច់
- ✓ ការផ្តល់សេវាស្តារនីតិសម្បទាត្រូវមានការប្រឹក្សា និងតម្រង់ទិសពី ប.ស.ស. ជាមុន
- ✓ មានភាពសមស្របនូវលក្ខខណ្ឌកាយសម្បទា សតិបញ្ញាកត្តាជំរុញ ឬសមត្ថភាពដែលអាចជំរុញបាន ព្រមទាំងឆន្ទៈសហការជាមួយអ្នកផ្តល់សេវា។

## របបសន្តិសុខសង្គម សេវាស្តារនីតិសម្បទា និងសមាជិក

| របប សន្តិសុខសង្គម | សេវា ស្តារនីតិសម្បទា | សមាជិក ប.ស.ស. | | | | |
|---|---|---|---|---|---|---|
| | | កម្មករ និយោជិត | មន្ត្រី រាជការ | អតីតមន្ត្រី រាជការ | អតីត យុទ្ធជន | បុគ្គលស្វ័យ និយោជន៍ |
| ផ្នែក ហានិភ័យការងារ | សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ | ✓ | ✓ | ✗ | ✗ | ✗ |
| | សេវាបណ្តុះបណ្តាលវិជ្ជាជីវៈ | ✓ | ✓ | ✗ | ✗ | ✗ |
| | ការសម្របសម្រួលការងារ | ✓ | ✓ | ✗ | ✗ | ✗ |
| | សេវាសង្គម | ✓ | ✓ | ✗ | ✗ | ✗ |
| ផ្នែក ថែទាំសុខភាព | សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ | ✓ | ✓ | ✓ | ✓ | ✓ |